# ព័ត៌មានសម្រាប់មាតាបិតា និងគ្រួសារ - Khmer

**តើ Premier's Reading Challenge (ការប្រកួតប្រជែងលើការអានរបស់អភិបាលរដ្ឋ) ជាអ្វី?**

Premier's Reading Challenge គឺជាកម្មវិធីលើកទឹកចិត្តផ្នែកអក្ខរកម្ម ដែលបានណែនាំឲ្យមានដោយអភិបាលរដ្ឋ ក្នុងឆ្នាំ ២០០៤ ដើម្បីៈ

- លើកទឹកចិត្តសិស្សឲ្យអានសៀវភៅបានច្រើន ហើយចូលចិត្តក្នុងការអាន
- កែលំអកម្រិតអក្ខរកម្ម។

ការប្រកួតប្រជែងនេះតម្រូវឲ្យសិស្សអានសៀវភៅចំនួន១២ក្បាលក្នុងរវាងដើមឆ្នាំសិក្សា និងដើមខែកញ្ញា។

**តើលោកអ្នករកឃើញច្រើនថែមទៀតអំពី ការប្រកួតប្រជែងដោយរបៀបណា?**

បើកមើលទំព័រ មាតាបិតា និងគ្រួសារនៃវ៉ិបសាយ Parents and Families ដើម្បីទទួលបាន ព័ត៌មានច្រើនថែមទៀត [http://www.premiersreadingchallenge.sa.edu.au/prc/pages/parents/families/](http://www.premiersreadingchallenge.sa.edu.au/prc/pages/parents/families/)

ទាក់ទងជាមួយភ្នាក់ងារទំនាក់ទំនងសហគមន៍ DECD ទូរស័ព្ទលេខៈ 8226 2756។

ទាក់ទងជាមួយសាលារៀនរបស់កូនលោកអ្នក។

**តើសៀវភៅណាខ្លះដែលសិស្សអាចអាន?**

សិស្សអាចអានសៀវភៅទាំងឡាយ ចេញពីបញ្ជីសៀវភៅ Premier's Reading Challenge ព្រមទាំងជម្រើសនៃសៀវភៅរបស់ខ្លួនផ្ទាល់ផងដែរ។ បញ្ជីសៀវភៅអាចទទួលយកបានពីវ៉ិបសាយ Premier's Reading Challenge។ សិស្សអាចជ្រើសរើសអានសៀវភៅជាភាសាផ្សេងពីភាសាអង់គ្លេស។

- ចាប់ពីសាលាថ្នាក់ត្រៀម ទៅថ្នាក់ទី៧ សិស្សជ្រើសរើសយកសៀវភៅយ៉ាងតិចណាស់៨ក្បាល ចេញពីបញ្ជីសៀវភៅនៅតាម វ៉ិបសាយ Premier's Reading Challenge និងសៀវភៅ៤ នៃជម្រើសរបស់ខ្លួនផ្ទាល់។
- ថ្នាក់ទី៨ និងថ្នាក់ទី៩ សិស្សជ្រើសរើសយកសៀវភៅយ៉ាងតិចណាស់៤ក្បាល ចេញពីបញ្ជីសៀវភៅ Premier's Reading Challenge និងសៀវភៅ៨ក្បាលនៃជម្រើសរបស់ខ្លួនផ្ទាល់។
- ថ្នាក់ទី១០ ថ្នាក់ទី៩១១ និងថ្នាក់ទី១២ សិស្សជ្រើសរើសយកសៀវភៅ១២ក្បាល នៃជម្រើសរបស់ខ្លួនផ្ទាល់។

**តើសៀវភៅទាំងនេះអាចរកបានពីកន្លែងណា?**

សៀវភៅទាំងនេះអាចរកបានពីសាលារៀន និងបណ្ណាល័យសាធារណៈ ហាងលក់សៀវភៅ និងហាងលក់សៀវភៅតាមតាមអ៊ីនធើណិត។

**តើមានរង្វាន់អ្វីខ្លះចំពោះការបំពេញ Premier's Reading Challenge?**

សញ្ញាប័ត្រ - ឆ្នាំទី១
មេដៃសំរិទ្ធ - ឆ្នាំទី២
មេដៃប្រាក់ - ឆ្នាំទី៣
មេដៃមាស - ឆ្នាំទី៤
មេដៃជើងឯក - ឆ្នាំទី៥
មេដៃកិត្តិយស - ឆ្នាំទី៦
មេដៃសាលកិត្តិនាម - ឆ្នាំទី៧
សញ្ញាប័ត្រអ្នកអានសម្រាប់មួយជីវិត (R4L):
សញ្ញាប័ត្រ R4L ឆ្នាំទី៨
សញ្ញាប័ត្រសំរិទ្ធ R4L – ឆ្នាំទី៩
សញ្ញាប័ត្រប្រាក់ R4L – ឆ្នាំទី១០
សញ្ញាប័ត្រមាស R4L – ឆ្នាំទី១១
សញ្ញាប័ត្រជើងឯក R4L – ឆ្នាំទី១២
សញ្ញាប័ត្រកិត្តិយស R4L – ឆ្នាំទី១៣
សញ្ញាប័ត្រសាលកិត្តិនាម R4L – ឆ្នាំទី១៤

**តើនរណាខ្លះជាអ្នកតំណាង Premier's Reading Challenge?**

ក្រុមកីឡាល្បីឈ្មោះប្រចាំរដ្ឋអូស្ត្រាលីខាងត្បូង៥នាក់ និងឯកអគ្គរដ្ឋទូត៦ជួយគាំទ្រដល់ Premier's Reading Challenge។ ក្រុមទាំងនេះមាន Adelaide United Football Club, Adelaide Lightning, Port Adelaide Football Club, Thunderbirds Netball Club, Adelaide Football Club និងក្រុមកីឡា cricket របស់ស្ត្រី Scorpions។

**តើមានសិស្សប៉ុន្មាននាក់ចូលរួមក្នុង Premier's Reading Challenge?**

រៀងរាល់ឆ្នាំ សិស្សច្រើនជា១២០,០០០នាក់ មកពី៩៥ភាគរយនៃសាលារៀនរដ្ឋអូស្ត្រាលីខាងត្បូង បំពេញ Premier's Reading Challenge។ សិស្សជាច្រើនអានសៀវភៅច្រើនជាង១២ក្បាល។

**តើការចូលរួមក្នុង Premier's Reading Challenge មានផលប្រយោជន៍អ្វីខ្លះ?**

- លើកទឹកចិត្តសិស្សរាល់រូបដើម្បីអានសៀវភៅបានច្រើន ហើយចូលចិត្តអានកាន់តែច្រើន។
- ឲ្យសិស្សចេះផ្តោតអារម្មណ៍លើការអានរបស់គេ។
- ផ្តល់នូវអារម្មណ៍នៃការបានសំរេចជោគជ័យ។
- លើកទឹកចិត្តដល់ការចូលរួមរបស់មាតាបិតានៅក្នុងការអានរបស់កូនខ្លួន។
- បង្កើនដល់ការខ្ចីសៀវភៅពីបណ្ណាល័យ។
- កែលំអផ្នែកអក្ខរកម្ម។